**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាខេត្តតាកែវ**
លេខ ៖ ១០៤.......សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស

## អភិបាលខេត្តតាកែវ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/២៩៨ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤ ស្តីពីការត្រាស់បង្គាប់តែងតាំងអភិបាល នៃគណៈអភិបាលខេត្តតាកែវ។
- បានឃើញអនុក្រឹត្រលេខ២១៦ អនក្រ/បក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០០៩ ស្តីពីការបែងចែកតួនាទីភារកិច្ច របៀបរបបការងាររបស់ក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត ក្រុមប្រឹក្សានិងគណៈអភិបាលក្រុង ក្រុមប្រឹក្សានិងគណៈអភិបាលស្រុក។
- យោងតាមផែនការអនុវត្តបីឆ្នាំដំណាក់កាលទីពីរ (២០១៥-២០១៧) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានអនុម័តដោយ គ.ជ.អ.ប កាលពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៤ ។
- យោងសេចក្តីណែនាំលេខ ០២៤ សណន/ គ.ជ.អ.ប ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការរៀបចំយន្តការគាំទ្រការអភិវឌ្ឍន៍ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។
- បានទទួលការអនុម័តពីក្រុមប្រឹក្សាខេត្តតាកែវ ក្នុងកិច្ចប្រជុំសាមញ្ញលើកទី១៥ នាថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥។

## សម្រេច

**ប្រការ ១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្តតាកែវដែលមានសមាសភាព ដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-លោក | **យស ណាស៊ី** | អភិបាលរងខេត្ត | ប្រធាន |
| ២-ឯកឧត្តម | **គិន ណែត** | សមាជិកក្រុមប្រឹក្សាខេត្ត | សមាជិក |
| ៣-លោកជំទាវ | **នាង គីមមុី** | សមាជិកក្រុមប្រឹក្សាខេត្ត | សមាជិក |
| ៤-លោក | **ដួង សោង** | នាយករងរដ្ឋបាលខេត្ត | សមាជិក |
| ៥-លោក | **ហ៊ឹម ម៉ាឡាយ៉ា** | នាយករងទីចាត់ការគ្រប់គ្រងធនធានមនុស្ស | សមាជិក |
| ៦-លោក | **ឌី ម៉ូថារី** | អនុប្រធានការិយាល័យកសាងសមត្ថភាព | លេខាធិការ |

- ចំពោះលេខាធិការ  មានសិទ្ធិចូលរួមប្រជុំ បញ្ចេញមតិ លើកយោបល់ តែមិនមានសិទ្ធិអនុម័តទេ។

**ប្រការ ២ ..**

គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្តមានតួនាទីដឹកនាំ សម្របសម្រួល តាមដានត្រួតពិនិត្យ និងវាយតម្លៃ លើការងារអភិវឌ្ឍន៍សមត្ថភាពរបស់ក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីបុគ្គលរដ្ឋបាលខេត្ត និងមានភារកិច្ចដូចខាងក្រោម ៖

- ធានាឱ្យមានការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍ស្ថាប័ន
- ផ្តល់ការណែនាំ ពិនិត្យ និងឯកភាពទៅលើសេចក្តីព្រាងផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំពាក់ព័ន្ធនិងការអភិវឌ្ឍន៍សមត្ថភាព ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត
- សម្របសម្រួលសកម្មភាពអភិវឌ្ឍន៍សមត្ថភាពនៅរដ្ឋបាលខេត្ត
- ពិនិត្យ ផ្តល់យោបល់ និងឯកភាពលើឯកសារ និងរបាយការណ៍អំពីការអភិវឌ្ឍន៍សមត្ថភាពរបស់រដ្ឋបាលខេត្ត
- កៀរគរធនធានសម្រាប់គាំទ្រការងារអភិវឌ្ឍន៍សមត្ថភាពរបស់រដ្ឋបាលខេត្ត ក្រុង ស្រុក
- ធានាថា ការគ្រប់គ្រងហិរញ្ញវត្ថុរបស់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត អនុវត្តបានត្រឹមត្រូវទៅតាមបែបបទ និងនីតិវិធីដែលបានកំណត់
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត
- ពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្តីពីវឌ្ឍនភាពនៃការអភិវឌ្ឍន៍សមត្ថភាពខេត្ត
- ធានាឲ្យមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត មានទីកន្លែងសមស្រប សម្រាប់បំពេញការងារមានឧបករណ៍ សម្ភារៈគ្រប់គ្រាន់សម្រាប់អនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន មានបន្ទប់ប្រជុំសមស្របសម្រាប់អនុវត្តសកម្មភាពនានា និងមានប្រព័ន្ធផ្តល់ព័ត៌មានទាន់ហេតុការណ៍ និងប្រព័ន្ធទុកដាក់តម្កល់ឯកសារ ។
- ប្រធានគណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស ជាមន្ត្រីស្នើសុំទូទាត់។
- លេខាធិការរបស់គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស ជាមន្ត្រីរៀបចំសំណើទូទាត់ ។

**ប្រការ ៣ ៈ**

គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត មានរបៀបរបបការងារដូចខាងក្រោម ៖

- គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត ក្នុងការបំពេញការងាររបស់ខ្លួន
- គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត ត្រូវជួបប្រជុំយ៉ាងតិច០២ខែម្តង និងតាមការចាំបាច់ ដើម្បីតាមដាន ត្រួតពិនិត្យ និងដោះស្រាយបញ្ហាប្រឈមនានា ដែលអាចកើតមាននៅក្នុងការអនុវត្តការងារពាក់ព័ន្ធការអភិវឌ្ឍសមត្ថភាព។
- កូរ៉ុមនៃកិច្ចប្រជុំ ត្រូវមានលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មាធិការទាំងមូល។
- ប្រធានគណៈកម្មាធិការ ជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មាធិការ។ ក្នុងករណីប្រធានអវត្តមាន ត្រូវផ្ទេរសិទ្ធិជាលាយល័ក្ខណ៍អក្សរទៅឱ្យសមាជិកណាមួយ ជាប្រធានស្តីទី។
- សេចក្តីសម្រេចរបស់អង្គប្រជុំគណៈកម្មាធិការអាចយកជាការបាន លុះត្រាតែមានសំឡេងអនុម័តលើសពីពាក់កណ្តាល នៃចំនួនសមាជិកគណៈកម្មាធិការទាំងមូល។ ប្រសិនបើសំឡេងអនុម័តមានចំនួនស្មើគ្នា សំឡេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព។
- ប្រធានគណៈកម្មាធិការ ត្រូវអញ្ជើញតំណាងក្រុមការងារបច្ចេកទេសចូលរួមប្រជុំនៅគ្រប់កិច្ចប្រជុំរបស់ខ្លួន។
- ប្រធានគណៈកម្មាធិការអាចអញ្ជើញប្រធានមន្ទីរ អង្គភាពជំនាញ តំណាងរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ អ្នកផ្តល់សេវាកម្មផ្នែកអភិវឌ្ឍន៍សមត្ថភាព និងអ្នកពាក់ព័ន្ធនានា ដើម្បីចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការ តាមការចាំបាច់។
- គ្រប់កិច្ចប្រជុំរបស់គណៈកម្មាធិការ ត្រូវមានកំណត់ហេតុ ដែលរៀបចំដោយលេខាធិការរបស់គណៈកម្មាធិការ និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។ ការិយាល័យកសាងសមត្ថភាពនៃទីចាត់ការគ្រប់គ្រងធនធានមនុស្សនៃសាលាខេត្ត ធ្វើជា សេនាធិការជូន គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត។

**ប្រការ ៤ ៈ**

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសនៃមណ្ឌលអភិវឌ្ឍន៍សមត្ថភាពខេត្ត រួមមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-លោក | **សេខ ផូ** | ទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ខេត្ត |
| ២-លោកស្រី | **ឡូន ចិន្តា** | ទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពខេត្ត |
| ៣-លោក | **ហ៊ាន លាន** | បុគ្គលិកសម្របសម្រួលក្រុមប្រឹក្សាខេត្ត |
| ៤-លោកស្រី | **លឹម គីមឌួច** | ទីប្រឹក្សាហិរញ្ញវត្ថុខេត្ត |
| ៥- ទីប្រឹក្សាហេដ្ឋានរចនាសម្ព័ន្ធខេត្ត | | |
| ៦-លោក | **យស តារម្យ** | បុគ្គលិកព័ត៌មានវិទ្យាខេត្ត |
| ៧-លោកស្រី | **ម៉ុត ម៉ុណ្ណារី** | ទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពស្រុក |

៨-លោក **អោម សិន** ទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពស្រុក

៩-លោក **ឌិត សារ៉េត** ទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពស្រុក

១០-លោក **ផាន ឃាង** បុគ្គលិកសម្របសម្រួលក្រុមប្រឹក្សាស្រុក

១១- បុគ្គលិកសម្របសម្រួលក្រុមប្រឹក្សាស្រុក

១២- បុគ្គលិកសម្របសម្រួលក្រុមប្រឹក្សាក្រុង ស្រុក

១៣-កញ្ញា **យុន រតនា** ជំនួយការការិយាល័យរដ្ឋបាល

**ប្រការ ៥ ..**

ក្រុមការងារបច្ចេកទេស មានតួនាទីអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៅមូលដ្ឋាន និងពីថ្នាក់ជាតិ និងមានភារកិច្ចដូចខាងក្រោម៖

- ផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងគោលបំណង រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងរបៀបទំនាក់ទំនងជាមួយមណ្ឌល ដល់ក្រុមប្រឹក្សា គណៈអភិបាល មន្ត្រីនៅរដ្ឋបាលថ្នាក់ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធនានា
- គាំទ្រដល់ក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីនៅរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ក្នុងការបកស្រាយបំភ្លឺនានាពាក់ព័ន្ធទៅនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ពង្រឹងសមត្ថភាពដល់ការិយាល័យកសាងសមត្ថភាព សំដៅជានាឱ្យរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់អាចគ្រប់គ្រង ចាត់ចែងកិច្ចការអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈឆ្លើយតប
- រៀបចំសេចក្តីព្រាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ សម្រាប់អភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រី បុគ្គលិកនៅរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ដើម្បីដាក់ជូនគណៈកម្មាធិការគ្រប់គ្រងមណ្ឌល គណៈអភិបាល និងក្រុមប្រឹក្សាពិនិត្យ ផ្តល់យោបល់ និងអនុម័ត។
- ធ្វើការប៉ាន់ប្រមាណតម្រូវការអភិវឌ្ឍន៍ស្ថាប័ន ការរៀបចំនិងធ្វើបច្ចុប្បន្នភាពផែនការអន្តរាគមន៍អភិវឌ្ឍន៍ស្ថាប័ន ការរៀបចំតាក់តែងនិងផ្តល់កិច្ចអន្តរាគមន៍អភិវឌ្ឍន៍ស្ថាប័ន និង ការវាយតម្លៃលទ្ធផលនៃការអភិវឌ្ឍស្ថាប័ន ស្របតាមខ្លឹមសារនៃសៀវភៅណែនាំស្តីពីការអភិវឌ្ឍស្ថាប័នសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ជានាឱ្យមានការបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមនៅក្នុងកិច្ចដំណើរការអភិវឌ្ឍន៍សមត្ថភាព រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលអំពីយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមប្រចាំឆ្នាំ ដល់ថ្នាក់ដឹកនាំនៃរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់
- រៀបចំ និងធ្វើបច្ចុប្បន្នភាពបញ្ជីអ្នកផ្តល់សេវាកម្មផ្នែកអភិវឌ្ឍន៍សមត្ថភាពនៅខេត្ត
- រៀបចំប្រព័ន្ធឆ្លើយតបទាន់ហេតុការណ៍ តាមរយៈការរៀបចំឱ្យមានប្រព័ន្ធទូរស័ព្ទ ទូរសារ និងអាសយដ្ឋានសារអេឡិចត្រូនិច ប្រព័ន្ធបណ្តាញសង្គម និងគេហទំព័រជាដើម សម្រាប់ទទួល និងឆ្លើយតបទៅនឹងសំណួរ ឬការស្នើសុំបំភ្លឺនានា ពីក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីនៅរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់

- សម្របសម្រួល អនុវត្ត និងផ្តល់កិច្ចអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាពនៅរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់
- រៀបចំប្រព័ន្ធទុកដាក់ឯកសារទាំងឯកសារអេឡិចត្រូនិច និងឯកសារបោះពុម្ព ដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់
- រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យអភិវឌ្ឍន៍សមត្ថភាពនៅរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់
- សម្របសម្រួលជ្រើសរើសអង្គភាព ឬអ្នកផ្តល់សេវាកម្មអភិវឌ្ឍន៍សមត្ថភាព ក្នុងការផ្តល់កិច្ចអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាពដល់រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ស្របតាមនីតិវិធីកំណត់
- គាំទ្រដល់ការរៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ អំពីលទ្ធផលនៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ព្រមទាំងរៀបចំតារាងបូកសរុបទិន្នន័យ នៃការអភិវឌ្ឍសមត្ថភាពតាមទម្រង់ទី៨។

**ប្រការ ៦ ..**

ក្រុមការងារបច្ចេកទេសត្រូវបំពេញការងារក្រោមការសម្របសម្រួលពីទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ខេត្ត និងមានរបៀបរបបការងារ ដូចខាងក្រោម ៖

- ក្រុមការងារបច្ចេកទេសទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ ចំពោះគណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត ក្នុងការបំពេញការងាររបស់ខ្លួនក្នុងក្របខ័ណ្ឌនៃមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត
- ក្រុមការងារបច្ចេកទេសត្រូវជួបប្រជុំយ៉ាងតិចមួយដង ក្នុងមួយខែ និងតាមការចាំបាច់ ក្រោមការសម្របសម្រួលរបស់ទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ខេត្ត
- គ្រប់កិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេស ត្រូវមានរបៀបវារៈ និងកំណត់ហេតុ។ កំណត់ហេតុកិច្ចប្រជុំ ត្រូវចម្លងជូនគណៈកម្មាធិការគ្រប់គ្រងមណ្ឌល ០១ច្បាប់។
- សមាជិកក្រុមការងារម្នាក់ៗ ត្រូវរៀបចំផែនការការងារប្រចាំខែ និងរៀបចំរបាយការណ៍លទ្ធផល អនុវត្តការងារប្រចាំខែរបស់ខ្លួន
- ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ក្រុមការងារបច្ចេកទេសត្រូវធ្វើទំនាក់ទំនងយ៉ាងជិតស្និទ្ធ និងជាប្រចាំជាមួយការិយាល័យកសាងសមត្ថភាព
- ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ក្រុមការងារបច្ចេកទេសអាចស្នើសុំមតិយោបល់ពីគណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស
- ក្រុមការងារបច្ចេកទេសត្រូវបែងចែកជាពីរក្រុម ដោយមួយក្រុមទទួលខុសត្រូវអភិវឌ្ឍន៍សមត្ថភាពក្រុមប្រឹក្សារដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ និងមួយក្រុមទៀតទទួលខុសត្រូវអភិវឌ្ឍន៍សមត្ថភាពគណៈអភិបាល និងមន្ត្រី បុគ្គលិករដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និង រដ្ឋបាលឃុំ សង្កាត់

- ក្រុមការងារបច្ចេកទេសត្រូវរៀបចំឱ្យមានទីប្រឹក្សា ឬបុគ្គលិករបស់មណ្ឌលប្រចាំការនៅរៀងរាល់ម៉ោងធ្វើការងារ ដើម្បីទទួល និងឆ្លើយតបទៅនឹងសំណួរ ឬសំណើ សំណូមពរនានារបស់ក្រុមប្រឹក្សា គណៈអភិបាល មន្ត្រី បុគ្គលិកនៅរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់និងអ្នកពាក់ព័ន្ធនានា ពាក់ព័ន្ធទៅនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

**ប្រការ ៧ ..**

សេចក្ដីសម្រេចទាំងឡាយណាដែលមានខ្លឹមសាផ្ទុយពីសេចក្ដីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨ ..**

លោកនាយករដ្ឋបាលសាលាខេត្ត លោកនាយកទីចាត់ការទាំង៥ និងអង្គភាពរបស់សាលាខេត្ត លោកប្រធានមន្ទីរអង្គភាពជុំវិញខេត្ត និងឯកឧត្តម លោកជំទាវ អស់លោក លោកស្រីដែលមានឈ្មោះក្នុង ប្រការ១ ប្រការ៤ ខាងលើ ត្រូវអនុវត្តសេចក្ដីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

តាកែវ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០១៥

**អភិបាលខេត្ត**

**ឡាយ វណ្ណៈ**

**ចម្លងជូន**

- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ
- លេខាធិការដ្ឋាន គ.ជ.អ.ប
- លេខាធិការដ្ឋានក្រុមប្រឹក្សាខេត្ត
  *"ដើម្បីជូនជ្រាប"*
- គ្រប់សាលាក្រុង ស្រុក និងឃុំ សង្កាត់
  *"ដើម្បីសហការអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ